**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០០០ ហិកតា ស្ថិតនៅភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

www.pheakdeylaw.com

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.០០០ ( ប្រាំបួនពាន់ ) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំតាឡាវ និងឃុំញ៉ាង ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ដើម្បីដាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម ក្រោមរូបភាពសម្បទានដីសេដ្ឋកិច្ច ដូចមានក្នុងផែនទី និងនិយាមកាលេខ ៨១១/១១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Pheakdey Law Book Store

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហឹង អាន អូរយ៉ាដាវ ខូអិលធីឌី ស្ថិតនៅក្នុង ឃុំតាឡាវ និងឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី




កូអរដោនេ ដីកាត់ចេញ :

| Coor x | Coor y | N | Coor x | Coor y | N |
|---|---|---|---|---|---|
| 741503. | 1551136. | a1 | 741751. | 1553462. | a17 |
| 741616. | 1551404. | a2 | 741368. | 1553044. | a18 |
| 741368. | 1551428. | a3 | 741569. | 1552877. | a19 |
| 741666. | 1552151. | a4 | 746042. | 1554055. | b1 |
| 741373. | 1552256. | a5 | 745428. | 1551889. | b2 |
| 741222. | 1552669. | a6 | 745238. | 1549974. | b3 |
| 740809. | 1551988. | a7 | 748034. | 1546481. | b4 |
| 740890. | 1551888. | a8 | 749726. | 1546885. | b5 |
| 741064. | 1551935. | a9 | 754589. | 1551055. | c1 |
| 741218. | 1551851. | a10 | 754852. | 1550062. | c2 |
| 741186. | 1551525. | a11 | 755585. | 1549770. | c3 |
| 741504. | 1552517. | a12 | 756000. | 1549260. | c4 |
| 741989. | 1552550. | a13 | 756392. | 1548811. | c5 |
| 741896. | 1552884. | a14 | 757048. | 1548000. | c6 |
| 742149. | 1553211. | a15 | 757619. | 1547422. | c7 |
| 741730. | 1553250. | a16 | 757924. | 1547143. | c8 |

**សញ្ញាសំគាល់ :**

- ស្រុក
- ឃុំ
- ភូមិ
- ចំនុចគោលព្រំ
- ចំនុចគោលតំបន់កាត់ចេញ
- ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច: ១៦.៨៥២ហ.ត
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវទឹក
- ផ្លូវ

**ចំនុចដែលប្រជាជនរស់នៅជិតដៃ :**

- ភូមិ
- ឃុំ
- ទីតាំងព្រំដែនទី២០៣
- សាលារៀន
- ទីតាំងចំការចន្ទី
- ទីតាំងដីស្រែ

**តំបន់ផ្សេងៗត្រូវកាត់ចេញ:**

| | | |
|---|---|---|
| | តំបន់ព្រៃកាត់ចេញ | ២.៨៦៧ហ.ត |
| | តំបន់ទ្រនាប់ព្រំប្រទល់ប្រទេស៥០០ម | ២៧៣ហ.ត |
| | តំបន់ដីស្រែរបស់ក្រុមហ៊ុន កាម៉ន សេណាន | ៨៥ហ.ត |
| | តំបន់ទ្រនាប់ផ្លូវទឹក | ៧៤៥ហ.ត |
| | សរុប | ៣.៩៧៨ហ.ត |

**តាមរូបភាព២០០៦ ផ្លូវឈើកាត់ចេញដីតំបន់ផ្សេងៗ:**

| | | |
|---|---|---|
| | ព្រៃស្រោង | ៣.៨៥៥ហ.ត |
| | ព្រៃពាក់កណ្តាលស្រោង | ១.០៥៦ហ.ត |
| | ព្រៃល្បោះ | ៣.៦៣៨ហ.ត |
| | ព្រៃឬស្សី | ២ហ.ត |
| | ព្រៃគុម្ពោតបៃតង | ៩១២ហ.ត |
| | ព្រៃគុម្ពោតស្ងួត | ៣៣ហ.ត |
| | ដីគ្មានគម្របព្រៃ | ៣.៣៣៨ហ.ត |
| | សរុប : | ១២.៩០៤ ហ.ត |

ផ្ទៃដីកាត់ពន្លំត្រូវប៉ាន់ប្រមាណ ៣.៩០៤ហ.ត

ផ្ទៃដីមិនកាត់ពន្លំ :

១៦.៨៥២ហ.ត - (៣.៩៧៨ហ.ត + ៣.៩០៤ហ.ត) = ៩.០០០ហ.ត







លេខ ១៤៨/១១

បានឃើញ និង ឯកភាព

សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

តាឡាវ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

មេឃុំ

សុផា សុម៉ុន

លេខ ៣៨៤/១១

បានឃើញ និង ឯកភាព

សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

ញ៉ាង ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

មេឃុំ

សេង ពើង

លេខ ០០៦/១១

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

អណ្តូងមាស ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

អភិបាលស្រុក

នង ដារិទ្ធ

លេខ ១៤២

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

រតនគិរី ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

ប្រធានមន្ទីរកសិកម្ម

សយ សុណា

លេខ ... /០១១

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

រតនគិរី ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

លេខ ៨១១/១១

បានឃើញ និងឯកភាព

ទឹម ស៊ីណាត គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច

រតនគិរី ថ្ងៃទី ... ខែ ៦ ឆ្នាំ ២០១១

អភិបាលខេត្ត

ប៉ាវ ហមផាន